ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ព្រឹទ្ធសភា
អគ្គលេខាធិការដ្ឋាន

# របាយការណ៍
# ស្តីពី
# លទ្ធផលការងាររបស់អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ប្រចាំឆ្នាំ២០១៧ និងទិសដៅការងារឆ្នាំ២០១៨

**សេចក្តីផ្តើម** :

នៅក្នុងឆ្នាំ២០១៧នេះ អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា បានខិតខំបំពេញការងារយ៉ាងសកម្ម និងមមាញឹកលើគ្រប់ការដ្ឋាន ដើម្បីផ្តល់សេវាជូនថ្នាក់ដឹកនាំ សមាជិក សមាជិកាព្រឹទ្ធសភា ក្នុងការអនុវត្តមុខងាររបស់ខ្លួនបានល្អប្រសើរតាមរយៈលទ្ធផលសំខាន់ៗដូចខាងក្រោមនេះ៖

## I.លទ្ធផលការងាររបស់អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា:

### ១.មុខងារនីតិកម្ម:

| របនាសម្ព័ន្ធនយោបាយ | របនាសម្ព័ន្ធរដ្ឋបាល |
|---|---|
| - ប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ចំនួន ២០លើក ប្រជុំពេញអង្គព្រឹទ្ធសភាចំនួន ០៧លើក និងប្រជុំវិសាមញ្ញចំនួន០៤លើក ដើម្បីពិនិត្យ និងឲ្យយោបល់លើសេចក្តីព្រាងច្បាប់ចំនួន១៣ច្បាប់ និងសេចក្តីស្នើច្បាប់ចំនួន០៩ច្បាប់<br>- បានរៀបចំប្រជុំផ្ទៃក្នុងគណៈកម្មការ និងប្រជុំអន្តរគណៈកម្មការព្រឹទ្ធសភា ជាមួយនឹងតំណាងរាជរដ្ឋាភិបាល និងតំណាងរដ្ឋសភាចំនួន១៣លើក ដើម្បីពិនិត្យ និងពិភាក្សាលើសេចក្តីស្នើច្បាប់ចំនួន០៩ច្បាប់ និងសេចក្តីព្រាងច្បាប់ចំនួន១៣ច្បាប់<br>- ប្រជុំគណៈកម្មការពិសេសចំនួន០៣លើក | - បានរៀបចំទីកន្លែង ចាត់ចែងនីតិវិធី ឯកសារពាក់ព័ន្ធ ធ្វើកំណត់ហេតុសង្ខេប និងពិស្តារនៃកិច្ចប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ ប្រជុំពេញអង្គ ប្រជុំវិសាមញ្ញព្រឹទ្ធសភា ប្រជុំអន្តរគណៈកម្មការ និងគណៈកម្មការពិសេសចំនួន៣៧លើក<br>- បានចូលរួមចំណែកកសាងសេចក្តីស្នើច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា<br>- បានចូលរួមចំណែកកសាងសេចក្តីស្នើវិសោធនកម្មបទបញ្ជាផ្ទៃក្នុងព្រឹទ្ធសភាថ្មី ក្រមសីលធម៌សមាជិកព្រឹទ្ធសភា ព្រមទាំងបានចូលរួមការងារក្នុងគណៈកម្មការ និងការបង្កើតលេខាធិការដ្ឋានក្រមសីលធម៌ព្រឹទ្ធសភា ដើម្បីជានាដំណើរការអនុវត្តឲ្យបានរលូន និងវិសោធនកម្មច្បាប់ស្តីពី |



វិមានរដ្ឋចំការមន មហាវិថីព្រះនរោត្តម រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទ: (855 23) 211 441, 211 442, 211 443 ទូរសារ: (855 23) 211 446, E-mail: oum_sarith@camnet.com.kh

| | |
|---|---|
| ដើម្បីពិនិត្យ ពិភាក្សាលើសេចក្តីស្នើច្បាប់ ស្តីពី ការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា ឯកសារ និងនីតិវិធីពាក់ព័ន្ធ<br>- ប្រជុំពិគ្រោះយោបល់សេចក្តីព្រាងបទបញ្ជា និងនីតិវិធីសម្រាប់ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ អាណត្តិទី៤ ឆ្នាំ២០១៧ ។ | លក្ខន្តិកៈមន្ត្រីរាជការនៃក្រុមនីតិប្បញ្ញត្តិត្រូវបានអនុម័ត ហើយកំពុងពិនិត្យ និងកែសម្រួលរចនាសម្ព័ន្ធតួនាទី ភារកិច្ច របស់អគ្គលេខាធិការដ្ឋាន-ព្រឹទ្ធសភា និងធ្វើបច្ចុប្បន្នភាពគោលនយោបាយ និងគោលការណ៍នានា ឲ្យស្របតាមការវិវត្ត និងការរីកចម្រើនរបស់ប្រទេសជាតិ<br>- បានសម្អាត តុបតែងសាល ផ្គត់ផ្គង់សម្ភារៈ ភេសជ្ជៈ និងអាហារសម្រន់សម្រាប់កិច្ចប្រជុំផ្សេងៗសរុបចំនួន១៤២លើក មានអ្នកចូលរួមចំនួន៧,៦៨៧នាក់<br>- បានថតចម្លងឯកសារបានចំនួន១៣៨សំណើ និងចងក្រងជាសៀវភៅចំនួន៦៨ក្បាល អស់ក្រដាសចំនួន២៦៦,៣២៣សន្លឹក<br>- បានផ្តល់សេវាដឹកជញ្ជូនសម្រាប់ថ្នាក់ដឹកនាំ សមាជិក សមាជិកាព្រឹទ្ធសភា និងមន្ត្រីរាជការនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ក្នុងរាជធានីភ្នំពេញ ចំនួន១០នាក់ ស្មើនឹង០២លើក<br>- បានផ្តល់សេវាថវិកាជូនថ្នាក់ដឹកនាំព្រឹទ្ធសភា និងមន្ត្រីរាជការនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ព្រមទាំងទូទាត់ការចំណាយផ្សេងៗចំនួន២០៤លើក<br>- បានការពារសន្តិសុខ សុវត្ថិភាព សណ្តាប់ធ្នាប់ ក្នុងកិច្ចប្រជុំផ្សេងៗ ដោយប្រើប្រាស់កម្លាំងសន្តិសុខផ្ទៃក្នុង និងកម្លាំងអន្តរាគមន៍ពីខាងក្រៅស្ថាប័ន ចំនួន៨៤៨នាក់ ស្មើនឹង៥៨លើក<br>- បានទទួលសេចក្តីព្រាងច្បាប់ចំនួន១៣ច្បាប់ និងសេចក្តីស្នើច្បាប់ចំនួន០៩ច្បាប់ ពីរដ្ឋសភា និងបានចាត់ចែងតាមនីតិវិធី<br>- បានទទួលព្រះរាជក្រម ព្រះរាជក្រឹត្យ អនុក្រឹត្យ |

| | |
|---|---|
| | សេចក្ដីសម្រេច ប្រកាស ដីកាអម និងលិខិតផ្សេងៗ ចំនួន៣,១៨៩ច្បាប់<br>- បានរៀបចំទីកន្លែងប្រជុំចំនួន៣១លើក ប្រចាំការថតសំឡេង ថតវីដេអូ និងរៀបចំប្រព័ន្ធសំឡេង ចំនួន១៨៩លើក<br>- ថត និងផ្សព្វផ្សាយព័ត៌មាន សេចក្ដីជូនដំណឹង សេចក្ដីប្រកាសព័ត៌មានចំនួន៨៣លើក<br>- បានបញ្ចូលឯកសារច្បាប់របស់ព្រឹទ្ធសភា នីតិកាលទី១ និងនីតិកាលទី២ ក្នុងគេហទំព័រ E-library ព្រឹទ្ធសភា ។ |

**២.មុខងារតាមដានការអនុវត្តច្បាប់ និងគោលនយោបាយនានា:**

| របនាសម្ព័ន្ធនយោបាយ | របនាសម្ព័ន្ធរដ្ឋបាល |
|---|---|
| - សមាជិក សមាជិកាព្រឹទ្ធសភា បានអញ្ជើញចុះបេសកកម្មតាមបណ្ដាខេត្ត ក្រុង រាជធានីភ្នំពេញចំនួន២៦លើក ដើម្បីសិក្សាឈ្វេងយល់អំពីការអនុវត្តច្បាប់ ការផ្សព្វផ្សាយច្បាប់ ការអនុវត្តគោលនយោបាយនានា ពិសេសគោលនយោបាយវិមជ្ឈការ និងវិសហមជ្ឈការនៅថ្នាក់ក្រោមជាតិ គោលនយោបាយភូមិ ឃុំ មានសុវត្ថិភាព និងការអនុវត្តសិទ្ធិមនុស្ស នៅខេត្តកំពត ព្រះសីហនុ កោះកុង កែប តាកែវ ព្រៃវែង ស្វាយរៀង កណ្ដាល កំពង់ចាម ត្បូងឃ្មុំ ប៉ៃលិន បាត់ដំបង ពោធិ៍សាត់ សៀមរាប ព្រះវិហារ ស្ទឹងត្រែង ក្រចេះ កំពង់ធំ កំពង់ឆ្នាំង រតនគិរី មណ្ឌលគិរី និងខេត្តបន្ទាយមានជ័យ ។ | - បានធ្វើលិខិតបេសកកម្មជូនសមាជិក សមាជិកាព្រឹទ្ធសភា និងមន្ត្រីរាជការនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភាចំនួន៣១៤នាក់ ស្មើនឹង៦៦ច្បាប់<br>- បានចាត់ចែងនីតិវិធី ធ្វើកំណត់ហេតុ ឬរបាយការណ៍ប្រជុំផ្ទៃក្នុងគណៈកម្មការនានាចំនួន៦៩លើក<br>- បានផ្ដល់សេវាដឹកជញ្ជូនសម្រាប់ថ្នាក់ដឹកនាំ សមាជិក សមាជិកាព្រឹទ្ធសភា និងមន្ត្រីរាជការនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា តាមបណ្ដាខេត្ត ក្រុង រាជធានីភ្នំពេញទាំង៨ភូមិភាគចំនួន៥៥នាក់ ស្មើនឹង០៦លើក<br>- បានផ្ដល់សេវាថវិកាជូនថ្នាក់ដឹកនាំព្រឹទ្ធសភា និងមន្ត្រីរាជការនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ចំនួន២០លើក ព្រមទាំងថ្លៃទិញសម្ភារៈ និងគ្រឿងអេឡិចត្រូនិច ចំនួន០២លើក<br>- បានថតចម្លងឯកសារចំនួន០៨សំណើ អស់ក្រដាស |

| | |
|---|---|
| | ចំនួន៣,៨៨៧សន្ទឹក<br>- បានការពារសន្តិសុខ សុវត្ថិភាព សណ្តាប់ធ្នាប់ក្នុងពិធីផ្សេងៗ ដោយប្រើប្រាស់កម្លាំងសន្តិសុខផ្ទៃក្នុងចំនួន១៣នាក់ ស្មើនឹង០១លើក<br>- ថត និងផ្សព្វផ្សាយសកម្មភាពរបស់សមាជិក សមាជិកាព្រឹទ្ធសភា ក្នុងកិច្ចប្រជុំ កិច្ចពិភាក្សាការងារ សិក្ខាសាលា និងការបំពេញបេសកកម្មនៅតាមបណ្តាខេត្ត ក្រុង រាជធានីភ្នំពេញទាំង៨ភូមិភាគចំនួន៥៩លើក ។ |

**៣.មុខងារតំណាង** :

| *របនាសម្ព័ន្ធនយោបាយ* | *របនាសម្ព័ន្ធរដ្ឋបាល* |
|---|---|
| - ថ្នាក់ដឹកនាំព្រឹទ្ធសភា បានចុះជួបសំណេះសំណាល សួរសុខទុក្ខ ចែកអំណោយ ដឹកនាំក្រុមគ្រូពេទ្យស្ម័គ្រចិត្តចុះពិនិត្យ និងព្យាបាលជំងឺជូនប្រជាពលរដ្ឋ ចូលរួមគោរពវិញ្ញាណក្ខន្ធ និងរំលែកទុក្ខដល់ក្រុមគ្រួសារសព នាំយកបច្ច័យ ទេយ្យវត្ថុ និងគ្រឿងបរិក្ខារទៅវេរប្រគេនព្រះសង្ឃបង្សុកូលឧទ្ទិសកុសលជូនដល់ដួងវិញ្ញាណក្ខន្ធសម្តេចអគ្គមហាធម្មពោធិសាល ជា ស៊ីម និងលោកជំទាវ និងបុព្វការីជន ដែលបានពលីជីវិត ពិនិត្យការដ្ឋានសាងសង់ ព្រមទាំងអញ្ជើញចូលរួមប្រជុំ ជាកិត្តិយស ជាអធិបតី និងពិធីផ្លូវការផ្សេងៗចំនួន១៩៧លើក នៅរាជធានីភ្នំពេញ ខេត្តព្រះសីហនុ កែប កំពត កំពង់ស្ពឺ ត្បូងឃ្មុំ កំពង់ចាម កំពង់ធំ | - រៀបចំបែបបទ ផ្តល់សេវា អមដំណើរថ្នាក់ដឹកនាំ សមាជិក សមាជិកាព្រឹទ្ធសភា អញ្ជើញចុះមូលដ្ឋាន ចូលរួមក្នុងកិច្ចប្រជុំ និងជាគណៈអធិបតីក្នុងពិធីផ្លូវការផ្សេងៗសរុបចំនួន៣,០៧៩លើក<br>- តុបតែងលម្អ ចងទង់ជាតិ ចងបដា ពាក្យស្លោក និងធ្វើហ្វុងអក្សរ ដើម្បីរៀបចំទទួលគណៈប្រតិភូក្នុងពិធីបុណ្យជាតិ អន្តរជាតិ បុណ្យសាសនា និងពិធីបុណ្យផ្សេងៗចំនួន៤០លើក<br>- បានសហការរៀបចំ និងចាត់ចែងពិធីគោរពវិញ្ញាណក្ខន្ធសពចំនួន១៦លើក<br>- បានផ្តល់សេវារដ្ឋបាល ពិធីការ និងទំនាក់ទំនងក្នុងដំណើរការរៀបចំកិច្ចប្រជុំ ការចុះស្រាវជ្រាវប្រមូលព័ត៌មាន ពិភាក្សាការងារ ការរៀបចំវេទិកា ការចុះតាមដានសិក្សាឈ្វេងយល់លទ្ធផលក្រោយការរៀបចំវេទិកា និងចូលរួមសន្និបាត ពិធីបំពាក់គ្រឿងឥស្សរិយយស ពិធីសម្ពោធអគារសិក្សា |

កំពង់ឆ្នាំង កណ្ដាល ពោធិ៍សាត់ ព្រៃវែង ស្ទឹងត្រែង តាកែវ ប៉ៃលិន រតនគិរី និង ខេត្តសៀមរាប

- សមាជិក សមាជិកាព្រឹទ្ធសភា បានចុះទៅតាមបណ្ដាខេត្ត ក្រុង រាជធានីភ្នំពេញ ទូទាំងប្រទេសចំនួន២,០៥៩លើក ដើម្បីចុះជួបពិភាក្សាការងារ សំណេះសំណាល សួរសុខទុក្ខប្រជាពលរដ្ឋ កងទ័ព សមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ ដឹកនាំក្រុមគ្រូពេទ្យស្ម័គ្រចិត្តចុះពិនិត្យ និងព្យាបាលជំងឺជូនប្រជាពលរដ្ឋ ពិនិត្យការដ្ឋានសាងសង់សម្ពោធសមិទ្ធផលនានា តាមដានការអនុវត្តគោលនយោបាយវិមជ្ឈការ និងវិសហមជ្ឈការនៅថ្នាក់ក្រោមជាតិ ការអនុវត្តគោលនយោបាយភូមិ ឃុំ មានសុវត្ថិភាព ឈ្វេងយល់អំពីស្ថានភាពសិទ្ធិមនុស្ស ការអនុវត្តច្បាប់ កែលម្អសេវាសាធារណៈ ពង្រឹងអភិបាលកិច្ចល្អនៅមូលដ្ឋាន និងគោលនយោបាយផ្សេងៗលើគ្រប់វិស័យ ព្រមទាំងបានចូលរួមក្នុងពិធីផ្លូវការ និងពិធីផ្សេងៗសរុបចំនួន៨២៣លើក
- ព្រឹទ្ធសភាបានទទួលពាក្យបណ្ដឹងចំនួន៥៤ករណី បញ្ជូនពាក្យបណ្ដឹងទៅអាជ្ញាធរ និងក្រសួងមានសមត្ថកិច្ចដោះស្រាយចំនួន៥៨ករណី ទទួលលិខិតឆ្លើយតបអំពីលទ្ធផលនៃការដោះស្រាយពាក្យបណ្ដឹងរបស់ក្រសួង ស្ថាប័ននានាចំនួន០៧ករណី ឆ្លើយតបទៅម្ចាស់បណ្ដឹងចំនួន

១ខ្នង មាន៥បន្ទប់ អណ្ដូងទឹក ស្រះទឹក កម្មវិធីមនុស្សធម៌ ព្រមទាំងកម្មវិធីផ្សេងៗចំនួន៧៩លើក
- បានរៀបចំទីកន្លែងសម្រាប់កិច្ចប្រជុំ សិក្ខាសាលា បទបង្ហាញ ពិធីចុះហត្ថលេខា ពិធីបំពាក់គ្រឿងឥស្សរិយយស ពិធីបើក និងបិទវគ្គបណ្ដុះបណ្ដាល និងកិច្ចពិភាក្សាផ្សេងៗចំនួន៨៦លើក
- សហការរៀបចំទីកន្លែងសម្រាប់វេទិកាចំនួន០៨លើក
- បានធ្វើបច្ចុប្បន្នភាពឯកសារស្ដីពី ស្ថិតិ និងទិន្នន័យក្រុមប្រឹក្សាឃុំ សង្កាត់ក្នុងភូមិភាគទាំង៨
- បានធ្វើលិខិតបេសកកម្មជូនសមាជិក សមាជិកា និងមន្ត្រីរាជការនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភាចំនួន២,៤២៦នាក់ ស្មើនឹង៥៦៤ច្បាប់ និងលិខិតអនុញ្ញាតច្បាប់ជូនសមាជិក សមាជិកាព្រឹទ្ធសភាចំនួន១០៧នាក់ ស្មើនឹង១០៧ច្បាប់
- បានថតចម្លងឯកសារបានចំនួន៩២សំណើ អស់ក្រដាសចំនួន៥០,១៤៣សន្លឹក
- បានផ្ដល់សេវាដឹកជញ្ជូនសម្រាប់ថ្នាក់ដឹកនាំ សមាជិក សមាជិកាព្រឹទ្ធសភា និងមន្ត្រីរាជការនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា តាមបណ្ដាខេត្ត ក្រុង រាជធានីភ្នំពេញទាំង៨ភូមិភាគចំនួន២,៥១៦នាក់ ស្មើនឹង៥១៦លើក
- បានផ្ដល់សេវាថវិកាជូនថ្នាក់ដឹកនាំ សមាជិក សមាជិកាព្រឹទ្ធសភា និងមន្ត្រីរាជការនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ព្រមទាំងទូទាត់ការចំណាយផ្សេងៗចំនួន៧៩៧លើក
- បានការពារសន្តិសុខ សុវត្ថិភាព សណ្ដាប់ធ្នាប់

| | |
|---|---|
| ៥៨ករណី ធ្វើកំណត់បង្ហាញពាក្យបណ្តឹងចំនួន៥៨ករណី ព្រមទាំងទទួលឯកសារជូនជ្រាបពីក្រសួង និងស្ថាប័នពាក់ព័ន្ធចំនួន៨៩ករណី<br>- ក្រុមសមាជិក សមាជិកាព្រឹទ្ធសភាប្រចាំភូមិភាគទី១ ,ទី២ ,ទី៥, ទី6 និងទី៨ បានរៀបចំវេទិកាសាធារណៈចំនួន០៨លើកស្តីពី ស្ត្រី និងច្បាប់ ការប្រជុំបូកសរុបលទ្ធផលការអនុវត្តផែនការអភិវឌ្ឍន៍មូលដ្ឋានឃុំ សង្កាត់ និងថ្នាក់ក្រោមជាតិជានាទូវសុវត្ថិភាពមូលដ្ឋាន ការផ្តល់សេវាសាធារណៈ និងការចូលរួមរបស់មហាជនក្នុងការអភិវឌ្ឍមូលដ្ឋានភូមិ សង្កាត់ កិច្ចពិគ្រោះយោបល់សាធារណៈ និងពង្រឹងសមត្ថភាពការងារកសាងផែនការអភិវឌ្ឍន៍មូលដ្ឋានការពង្រឹងសមត្ថភាពក្រុមប្រឹក្សាឃុំ សង្កាត់អាណត្តិទី២ ការផ្សព្វផ្សាយសមិទ្ធផលសំខាន់ៗរបស់ព្រឹទ្ធសភា និងភាពជាតំណាងរបស់ក្រុមសមាជិកព្រឹទ្ធសភានិងការពន្យល់អំពីការបោះឆ្នោត និងការវិភាគទាន នៅរាជធានីភ្នំពេញ ខេត្តរតនគិរីប៉ៃលិន កែប កំពត តាកែវ ស្វាយរៀង និងខេត្តព្រៃវែង ។ | ក្នុងពិធីផ្សេងៗ ដោយប្រើប្រាស់កម្លាំងសន្តិសុខផ្ទៃក្នុងចំនួន៦៧នាក់ ស្មើនឹង៣០លើក<br>- បានទទួលលិខិតចូលចំនួន១១,២៧៩ច្បាប់ និងបញ្ជូនលិខិតចេញចំនួន១,៣៣១ច្បាប់<br>- បានចុះសួរសុខទុក្ខសមាជិកព្រឹទ្ធសភា និងមន្ត្រីរាជការដែលមានជំងឺ និងលំហែមាតុភាព ព្រមទាំងនិវត្តជននៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភាចំនួន៥០នាក់<br>- រៀបចំពិធីជួបសំណេះសំណាលជាមួយនិវត្តជននិងមន្ត្រីរាជការវ័យចំណាស់នៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភាឆ្នាំ២០១៧<br>- ផ្តល់រូបថតចំនួន១១,១៥៧សន្លឹក និងអត្ថបទសារព័ត៌មានចំនួន២១៣អត្ថបទ<br>- ទទួលមន្ត្រីរាជការ សិស្ស និស្សិត និងសាធារណជនចូលអានសៀវភៅចំនួន១,៩៧៣នាក់ ធ្វើប័ណ្ណសមាជិកចំនួន៧៨នាក់ ខ្ចីសៀវភៅចំនួន៦០០ក្បាល និងសងវិញចំនួន២៣៣ក្បាល<br>- បានសម្របសម្រួលទទួលដំណើរទស្សនកិច្ចសិក្សានៅព្រឹទ្ធសភាចំនួន១៣លើក រួមមានស្ថានទូតក្រសួង ប្រជាពលរដ្ឋ សាស្ត្រាចារ្យ សិស្ស និងនិស្សិតសរុបចំនួន៥៦៧នាក់<br>- ផ្តល់ឯកសារ និងសៀវភៅរបស់ព្រឹទ្ធសភា និងអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ដល់បណ្ណាល័យនៃរាជបណ្ឌិតសភា បណ្ណាល័យនៃទីចាត់ការការងារព្រំដែន សាលាកងទ័ពការពារព្រំដែន អគ្គមេបញ្ជាការដ្ឋាននៃបណ្តោយព្រំដែនកម្ពុជា ឡាវ ថៃ មន្ទីរទំនាក់ទំនងរដ្ឋសភា និងព្រឹទ្ធសភាប្រចាំ |

| | |
|---|---|
| | ខេត្តប៉ៃលិន សាកលវិទ្យាល័យបៀលប្រាយ សាខាខេត្តស្ទឹងត្រែង ក្រសួង ស្ថាប័ន អង្គការ និងបណ្ណាល័យនានាចំនួន៣,៥០៣ក្បាល<br>- ទទួលឯកសារ សៀវភៅពីអង្គការ ស្ថានទូត ក្រសួង ស្ថាប័ន គ្រឹះស្ថានអប់រំ សប្បុរសជន និងអង្គភាពចំណុះអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ព្រឹត្តិបត្រទស្សនាវដ្ដី និងរាជកិច្ចចំនួន៥,៥៥៨ក្បាល កាសែត និងព្រះរាជក្រមចំនួន១,៩១៣ច្បាប់<br>- បានផលិតព័ត៌មានទាន់ហេតុការណ៍ និងផលិតវីដេអូសម្រាប់បង្ហោះលើ Alert News ចំនួន ៣,៨៨៩ប្រធានបទ<br>- បានថត និងផ្សព្វផ្សាយព័ត៌មានផ្សេងៗចំនួន ៨៧៧លើក<br>- បានដកស្រង់ ចងក្រង និងផ្សព្វផ្សាយព័ត៌មានសង្ខេបប្រចាំថ្ងៃសរុបចំនួន៦១៤លើក ។ |

**៤.មុខងារសហប្រតិបត្តិការអន្តរជាតិ និងទំនាក់ទំនងសាធារណៈ :**

| រចនាសម្ព័ន្ធនយោបាយ | រចនាសម្ព័ន្ធរដ្ឋបាល |
|---|---|
| - ថ្នាក់ដឹកនាំព្រឹទ្ធសភា បានអនុញ្ញាតឲ្យគណៈប្រតិភូជាតិ អន្តរជាតិ ឥស្សរជន-នយោបាយ អគ្គទូត និងអង្គការអន្តរជាតិនានា ចូលជួបជូនសារតាំង សម្ដែងការគួរសម សវនាការ និងជម្រាបលាចំនួន ៤២លើក<br>- សមាជិក សមាជិកាព្រឹទ្ធសភា បានជួបពិភាក្សាការងារ និងសម្ដែងការគួរសមជាមួយភ្ញៀវជាតិ និងអន្តរជាតិចំនួន ៤៧លើក | - បានរៀបចំពិធីបដិសណ្ឋារកិច្ច ដំណើរទស្សនកិច្ចផ្លូវការរបស់គណៈប្រតិភូអន្តរជាតិ ឥស្សរជននយោបាយ អគ្គទូត និងអង្គការអន្តរជាតិនានា<br>- រៀបចំទីកន្លែងសម្រាប់ជូនសារតាំង ជំនួបសម្ដែងការគួរសម សវនាការ និងជម្រាបលា ព្រមទាំងពិធីផ្សេងៗចំនួន៤២លើក<br>- បានថត និងផ្សព្វផ្សាយសកម្មភាពថ្នាក់ដឹកនាំជួបភ្ញៀវជាតិ និងអន្តរជាតិ មកបំពេញទស្សនកិច្ចចំនួន ៣២៩លើក |

| | |
|---|---|
| - ថ្នាក់ដឹកនាំ និងសមាជិក សមាជិកាព្រឹទ្ធសភា បានអញ្ជើញទៅបំពេញទស្សនកិច្ចសិក្សា ចូលរួមកិច្ចប្រជុំ មហាសន្និបាត សន្និសីទ វេទិកា សិក្ខាសាលា និងពិធីផ្សេងៗចំនួន២៨លើក នៅព្រះរាជាណាចក្រថៃឡង់ដ៍ ព្រះរាជាណាចក្រជប៉ុន ព្រះរាជាណាចក្រប៊ូតាន សាធារណរដ្ឋប្រជាមានិតចិន សាធារណរដ្ឋសង្គមនិយមវៀតណាម សាធារណរដ្ឋហ្វីជី សាធារណរដ្ឋបារាំង សាធារណរដ្ឋកូរ៉េ សាធារណរដ្ឋហ្វីលីពីន សាធារណរដ្ឋសិង្ហបុរី សាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ សាធារណរដ្ឋអ៊ីស្លាមប៉ាគីស្ថាន សហភាពសហព័ន្ធរុស្ស៊ី ប្រទេសស៊ុយអែត ប្រទេសតួកគី ប្រទេសហុងគ្រី ប្រទេសបង់ក្លាដេស ប្រទេសឥណ្ឌូនេស៊ី ប្រទេសលុចហ្សំបួរ ប្រទេសប៊ែលហ្ស៊ិក និងប្រទេសឥណ្ឌា ។ | - បានរៀបចំសម្អាត តុបតែងសាល ផ្តល់សេវាភេសជ្ជៈ អាហារសម្រន់ និងផ្គត់ផ្គង់សម្ភារៈអនាម័យក្នុងពិធីផ្សេងៗចំនួន១៨១លើក ស្មើនឹង១,២៦៨នាក់<br>- បានថតចម្លងឯកសារចំនួន៤៩ច្បាប់ អស់ក្រដាសចំនួន២៣,០៥៣សន្លឹក<br>- បានផ្តល់សេវាដឹកជញ្ជូនជូនថ្នាក់ដឹកនាំ សមាជិក សមាជិកាព្រឹទ្ធសភា និងមន្ត្រីរាជការនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា តាមបណ្តាខេត្ត ក្រុងរាជធានីភ្នំពេញទាំង៨ភូមិភាគចំនួន៧៣៦នាក់ ស្មើនឹង២៥៥លើក<br>- បានផ្តល់សេវាថវិកាជូនថ្នាក់ដឹកនាំព្រឹទ្ធសភា និងមន្ត្រីរាជការនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ព្រមទាំងទូទាត់ការចំណាយផ្សេងៗចំនួន១៤៤លើក<br>- ធ្វើកំណត់បង្ហាញ កំណត់ហេតុ ធ្វើសំណើ និងលិខិតឆ្លើយតបទៅក្រសួងផ្សេងៗ និងបណ្តាអង្គទូតនានាចំនួន១៣៥លើក<br>- បានធ្វើលិខិតបេសកកម្មជូនសមាជិក សមាជិកាព្រឹទ្ធសភា និងមន្ត្រីរាជការនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភាចំនួន៤៤៩នាក់ ស្មើនឹង១០៩ច្បាប់<br>- បានរៀបចំកញ្ចប់ថវិកាដំណើរបេសកកម្មជូនសមាជិក សមាជិកាព្រឹទ្ធសភា ទៅបំពេញបេសកកម្មក្រៅប្រទេសចំនួន២៨លើក<br>- បានការពារសន្តិសុខ សុវត្ថិភាព សណ្តាប់ធ្នាប់ក្នុងកិច្ចប្រជុំផ្សេងៗ ដោយប្រើប្រាស់កម្លាំងសន្តិសុខផ្ទៃក្នុងចំនួន៦៧នាក់ ស្មើនឹង៦០លើក<br>- អគ្គលេខាធិការព្រឹទ្ធសភា បានជួបពិភាក្សាការងារជាមួយភ្ញៀវជាតិ និងអន្តរជាតិចំនួន១១លើក |

| | |
|---|---|
| | ព្រមទាំងបានអញ្ជើញចូលរួមកិច្ចប្រជុំ និងបំពេញទស្សនកិច្ចនៅក្រៅប្រទេសចំនួន០៤លើក នៅសាធារណរដ្ឋបារាំង សហភាពសហព័ន្ធរុស្ស៊ី ប្រទេសបង់ក្លាដេស និងប្រទេសលុចហ្សំបួរ<br>- រៀបចំបែបបទជូនថ្នាក់ដឹកនាំ និងមន្ត្រីរាជការនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ទៅបំពេញទស្សនកិច្ចសិក្សា ចូលរួមកិច្ចប្រជុំ សន្និបាត វេទិកា សិក្ខាសាលា និងពិធីផ្សេងៗចំនួន២១លើក នៅព្រះរាជាណាចក្រថៃឡង់ដ៍ ព្រះរាជាណាចក្រជប៉ុន សាធារណរដ្ឋសង្គមនិយមវៀតណាម សាធារណរដ្ឋប្រជាមានិតចិន សហភាពសហព័ន្ធរុស្ស៊ី សាធារណរដ្ឋបារាំង សាធារណរដ្ឋសិង្ហបុរី សាធារណរដ្ឋកូរ៉េ ប្រទេសឥណ្ឌា ប្រទេសលុចហ្សំបួរ ប្រទេសអង់គ្លេស និងប្រទេសប៉ូឡូញ<br>- ទំនាក់ទំនងជាមួយស្ថានទូតបារាំង ស្ថានទូតចិន ស្ថានទូតឥណ្ឌា ស្ថានទូតសិង្ហបុរី ព្រឹទ្ធសភាបារាំង សភាសហព័ន្ធវ៉ាល់ឡូនី ព្រុចសែល វិទ្យាស្ថានបារាំង មជ្ឈមណ្ឌលHRD សមាគមបេសកកម្មសិក្សាអាស៊ី អ្នកជំនាញបច្ចេកទេសព័ត៌មាន ក្រសួង ស្ថាប័ន បណ្ណាល័យនានា ដើម្បីសុំ និងទទួលសៀវភៅ ព្រឹត្តិបត្រ សម្រួលដល់កិច្ចការអន្តរជាតិ ដំណើរទស្សនកិច្ច សិក្ខាសាលា បំពេញបេសកកម្មក្នុង និងក្រៅប្រទេស ស្នើសុំអាហារូបករណ៍ វគ្គបណ្ដុះបណ្ដាល ព្រមទាំងការរៀបចំពិធីផ្សេងៗ ។ |

## ៥.មុខងារអភិវឌ្ឍន៍ស្ថាប័ន :

| រចនាសម្ព័ន្ធនយោបាយ | រចនាសម្ព័ន្ធរដ្ឋបាល |
|---|---|
| | + បានពិនិត្យផ្ដល់យោបល់ និងចុះហត្ថលេខាលើ |

| | |
|---|---|
| | ឯកសារផ្សេងៗចំនួន១,៣៦៣ច្បាប់<br>- បានវាយតម្លៃការអនុវត្តផែនការប្រតិបត្តិសម្រាប់ត្រីមាសទី១ ឆមាសទី១ នព្វមាស និងប្រចាំឆ្នាំ២០១៧<br>- បានធ្វើរបាយការណ៍ចន្លោះសម័យប្រជុំលើកទី៩ លើកទី១០ និងលើកទី១១ នីតិកាលទី៣<br>- បានធ្វើបច្ចុប្បន្នភាពផែនការយុទ្ធសាស្ត្រ១០ឆ្នាំ<br>- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា បានត្រៀមបញ្ចប់ការងារ នីតិកាលទី៣ ព្រឹទ្ធសភា និងការចាប់ផ្តើមនីតិកាលទី៤ដោយរលូន ដែលតម្រូវឲ្យត្រៀមការងារពហុវិស័យជាមុនឲ្យបានគ្រប់ជ្រុងជ្រោយ។<br>+ការងារគ្រប់គ្រងបុគ្គលិក:<br>- បានរៀបចំលិខិតបទដ្ឋានផ្សេងៗពាក់ព័ន្ធនឹងការគ្រប់គ្រងមន្ត្រីរាជការសរុបចំនួន៣៩៧ច្បាប់<br>- រៀបចំលេខាធិការដ្ឋានក្រុមសីលធម៌ គណៈកម្មការក្រុមសីលធម៌ ការពិចារណារៀបចំយន្តការរបស់ព្រឹទ្ធសភានីតិកាលទី៤<br>- បានបញ្ចប់ការកែសម្រួលបទបញ្ជាផ្ទៃក្នុងរបស់អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ឲ្យស្របតាមស្ថានភាពជាក់ស្តែង និងពិនិត្យ ពិភាក្សាអំពីក្រមសីលធម៌សម្រាប់មន្ត្រីរាជការ<br>- បានរៀបចំធ្វើនិយ័តកម្មមន្ត្រីរាជការនៃអគ្គលេខា-ធិការដ្ឋានព្រឹទ្ធសភា<br>- បានរៀបចំធ្វើសមាហរណកម្មមន្ត្រីរាជការនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភាទៅក្នុងក្របខ័ណ្ឌថ្មី<br>- បានរៀបចំវាយតម្លៃតាំងស៊ប់មន្ត្រីរាជការនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភាក្នុងមុខតំណែង |

| | |
|---|---|
| | គ្រប់គ្រង<br>- បានពិនិត្យ និងវាយតម្លៃតម្លើងថ្នាក់បៀវត្ស និងប្រាក់បំណាច់មន្ត្រីរាជការនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា<br>- បានរៀបចំស្នើសុំគ្រឿងឥស្សរិយយសជូនមន្ត្រីរាជការនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ដែលមានស្នាដៃសម្រាប់ឆ្នាំ២០១៦ និងការត្រៀមគ្រឿងឥស្សរិយយសលើកទី២ ជូនសមាជិក សមាជិកាព្រឹទ្ធសភា<br>- បានរៀបចំកាត់ឯកសណ្ឋានជូនមន្ត្រីរាជការនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភាឆ្នាំ២០១៧<br>- បានចុះដំណើរមន្ត្រីរាជការ បុគ្គលិកជាប់កិច្ចសន្យា និងអ្នកហាត់ការនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា<br>- បានបូកសរុបលទ្ធផលការងារព្រឹទ្ធសភានីតិកាលទី៣ (២០១២-២០១៨) និងព្រឹទ្ធសភា៣នីតិកាល (១៩៩៩-២០១៨)<br>- បានបោះពុម្ពសៀវភៅក្របខ័ណ្ឌយុទ្ធសាស្ត្រ និងផែនការសកម្មភាពសម្រាប់ពង្រឹងសមត្ថភាពព្រឹទ្ធសភាកម្ពុជា (២០១៨-២០២៤) ក្នុងបរិបទព្រឹទ្ធសភានីតិកាលទី៤ (២០១៨-២០២៤) ជាភាសាខ្មែរ ភាសាអង់គ្លេស និងកំពុងចាត់ចែងការបកប្រែជាភាសាបារាំង<br>- បានផលិតប័ណ្ណជូនពរចូលឆ្នាំសកលឆ្នាំ២០១៨ និងចូលឆ្នាំថ្មីប្រពៃណីជាតិខ្មែរចំនួន៦០,៩៥០សន្លឹក ទស្សនាវដ្តីព្រឹទ្ធសភាប្រចាំខែមករា ដល់ខែធ្នូ ឆ្នាំ២០១៧ចំនួន៣០,០០០ក្បាល ស្លាករថយន្តចេញនិងចូលព្រឹទ្ធសភា ឆ្នាំ២០១៨ ចំនួន២,៩០០ សន្លឹក ព្រមទាំងផលិត និងផ្សព្វផ្សាយវីដេអូស្ដីពី |

| | |
|---|---|
| | សមិទ្ធផលព្រឹទ្ធសភាប្រចាំឆ្នាំទី៤ នីតិកាលទី៣ ចំនួន០១លើក<br>- បានចាត់ចែងការបោះពុម្ពដំណាច់ឆ្នាំ ទិនានុលេខន៍ និងប្រតិទិន ។<br>+ការងារបណ្តុះបណ្តាលធនធានមនុស្ស :<br>- កិច្ចសហប្រតិបត្តិការជាមួយដៃគូ ដើម្បីអភិវឌ្ឍន៍ធនធានមនុស្ស និងអភិវឌ្ឍន៍ស្ថាប័ន<br>- ការបណ្តុះបណ្តាលធនធានមនុស្សក្នុង និងក្រៅប្រទេសសរុបចំនួន១០៣វគ្គ មានសិក្ខាកាមចូលរួមចំនួន១,០៩៨នាក់ សិក្ខាសាលាក្នុង និងក្រៅប្រទេសចំនួន០៦លើក មានសិក្ខាកាមចូលរួមសរុបចំនួន១៧៨នាក់<br>- កសាងផែនការបណ្តុះបណ្តាល និងអភិវឌ្ឍន៍ធនធានមនុស្សនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភារយៈពេល០៥ឆ្នាំ (២០១៧-២០២១)<br>- បានសហការជាមួយវិទ្យាស្ថានសភាកម្ពុជា(PIC) បើកវគ្គបណ្តុះបណ្តាលភាសាអង់គ្លេសសម្រាប់មន្ត្រីសភា វគ្គស្រាវជ្រាវសភា បន្តវគ្គ PBO ការងារព័ត៌មាន និងទំនាក់ទំនងសាធារណៈ<br>- ទទួលអ្នកឯកទេសជាន់ខ្ពស់ឥណ្ឌា មកជួយបណ្តុះបណ្តាល និងផ្តល់យោបល់អំពីការរៀបចំអគ្គនាយកដ្ឋានស្រាវជ្រាវ ។<br>+ចាត់ចែងការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ :<br>- ប្រជុំគណៈកម្មការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ជាមួយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ |

| | |
|---|---|
| | - បានរៀបចំគម្រោងថវិកាឆ្នាំ២០១៨ និងរៀបចំបែងចែកថវិកាឆ្នាំ២០១៨<br>- បានពិនិត្យគម្រោងថវិកាតាមកម្មវិធីឆ្នាំ២០១៨<br>- រៀបចំគោលការណ៍ហិរញ្ញវត្ថុសម្រាប់នីតិកាលទី៤<br>- បានសិក្សាអំពីគោលការណ៍បង្កើតអង្គភាពថវិការបស់ព្រឹទ្ធសភា ឆ្នាំ២០១៧<br>- បានពិនិត្យ និងពិភាក្សាអំពីសមត្ថកិច្ចសវនកម្មក្នុងក្របខ័ណ្ឌស្ថាប័ន<br>- ធ្វើរបាយការណ៍ចំណូល ចំណាយថវិកាឆ្នាំ២០១៦ ជូនគណៈកម្មាធិការអចិន្ត្រៃយ៍ និងការបែងចែកឥណទានរបស់ព្រឹទ្ធសភា ប្រចាំឆ្នាំ២០១៧<br>- បានរៀបចំរបាយការណ៍ចំនួនមន្ត្រីក្របខ័ណ្ឌ និងបុគ្គលិកជាប់កិច្ចសន្យា របាយការណ៍ប្រាក់បៀវត្ស ប្រាក់បំណាច់ និងប្រាក់វិភាជន៍ផ្សេងៗ និងរបាយការណ៍ចំណាយថវិកាធៀបអាណត្តិប្រចាំខែ និងប្រចាំឆ្នាំ២០១៧ ផ្ញើជូនក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ<br>- បានបើកសំណើដេញថ្លៃជាសាធារណៈស្តីពីការផ្គត់ផ្គង់ និងការបោះពុម្ព<br>- បានវាយតម្លៃលទ្ធកម្មសាធារណៈ<br>- បានទូទាត់ថ្លៃលទ្ធកម្មថ្លៃទិញសម្ភារៈ គ្រឿងអេឡិច-ត្រូនិច គ្រឿងសំណង់ និងទំនិញផ្សេងៗចំនួន ៥៧០លើក<br>- បានផ្គត់ផ្គង់វត្ថុអនុស្សាវរីយ៍ គ្រឿងបរិក្ខារផ្សេងៗ និងអាហារសម្រន់សម្រាប់កិច្ចប្រជុំនានាចំនួន ១៩៧សំណើ និងផ្គត់ផ្គង់សម្ភារៈអនាម័យ សម្ភារៈការិយាល័យ និងភេសជ្ជៈចំនួន៥០២សំណើ |

| | |
|---|---|
| | ជូនគ្រប់អង្គភាពចំណុះអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា<br>- បានរៀបចំសម្អាត តុបតែងសាល ផ្តល់សេវាគេសជ្ជៈ និងអាហារសម្រន់ក្នុងពិធីផ្សេងៗចំនួន៥០២លើក មានអ្នកចូលរួមចំនួន១០,៨១០នាក់<br>- បានផ្តល់សេវាថវិកាជូនថ្នាក់ដឹកនាំព្រឹទ្ធសភា និងមន្ត្រីរាជការនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ព្រមទាំងបានទូទាត់ការចំណាយផ្សេងៗចំនួន ១,៥៣២លើក<br>- បានថតចម្លងឯកសារបានចំនួន៥៧៥សំណើ និងធ្វើជាសៀវភៅចំនួន៤៧១ក្បាល អស់ក្រដាសចំនួន២៧០,១១៩សន្លឹក<br>- ផ្តល់សេវាដឹកជញ្ជូនសម្រាប់ថ្នាក់ដឹកនាំ សមាជិក សមាជិកាព្រឹទ្ធសភា និងមន្ត្រីរាជការនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ក្នុងរាជធានីភ្នំពេញចំនួន ១,៨០៧នាក់ ស្មើនឹង៦៦២លើក ។<br>+ការកសាង និងជួសជុលហេដ្ឋារចនាសម្ព័ន្ធរូបវន្ត រឹង និងទន់:<br>- រៀបចំបែបបទសុំជំនួយពីសាធារណរដ្ឋប្រជាមានិតចិន ដើម្បីសាងសង់សាលប្រជុំពេញអង្គថ្មី<br>- បានធ្វើបែបបទស្នើសុំជំនួយពីប្រទេសជាមិត្ត សម្រាប់នីតិកាលទី៤ព្រឹទ្ធសភា<br>- សមិទ្ធផលថ្មីរបស់ព្រឹទ្ធសភា បានទទួលអគារការិយាល័យថ្នាក់ដឹកនាំចំនួន១ខ្នង កំពស់៣ជាន់ ដែលជាជំនួយឥតសំណងរបស់រដ្ឋាភិបាលនៃសាធារណរដ្ឋប្រជាមានិតចិន ជូនដល់ព្រឹទ្ធសភា<br>- ចាត់ចែងជួសជុលសាលប្រជុំពេញអង្គ និងបញ្ចប់ដំណើរការជួសជុលអគារមូលនិធិខ្មែរអភិវឌ្ឍន៍ |

| | |
|---|---|
| | - ជួសជុល កែលម្អហេដ្ឋារចនាសម្ព័ន្ធ អគារ ផ្លូវថ្នល់ លូទឹក និងផ្លាស់ប្តូរគ្រឿងអគ្គិសនី គ្រឿងអេឡិចត្រូនិចចំនួន១,៦៣៨គ្រឿង<br>- ជួសជុលសម្ភារៈការិយាល័យ និងគ្រឿងសង្ហារឹម ចំនួន៣៥៧គ្រឿង<br>- បានទទួលសម្ភារៈបច្ចេកទេសដែលជាអំណោយ របស់រដ្ឋសភាវៀតណាម<br>- រៀបចំកែលម្អបរិស្ថានក្នុងបរិវេណព្រឹទ្ធសភា ឲ្យមានសោភ័ណ្ឌភាពល្អ<br>- ធ្វើពិព័រណ៍រូបភាពនៅព្រឹទ្ធសភាចំនួន២៨លើក<br>- បិទលេខកូដសម្ភារៈសារពើភ័ណ្ឌចំនួន២១៨គ្រឿង<br>- រៀបចំប្រទីបព្រឹទ្ធសភា ដើម្បីចូលរួមក្នុងពិធីបុណ្យ អុំទូក បណ្តែតប្រទីប និងសំពះព្រះខែ អកអំបុក<br>- បានរៀបចំប្រព័ន្ធគ្រប់គ្រងទិន្នន័យ ( NAS ) ជូន អគ្គនាយកដ្ឋានទាំងបី និងអង្គភាពចំណុះអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា<br>- ចុះត្រួតពិនិត្យ តាមដានប្រព័ន្ធNetwork Internet Connect Wifi និងជួសជុលម៉ាស៊ីនកុំព្យូទ័រ ដាក់កម្មវិធីកំចាត់មេរោគ Update Files Antivirus បញ្ចូលកម្មវិធី Unicode និងSet up កម្មវិធីសរុប ចំនួន៩៣០គ្រឿង។ បានUpload សេចក្តីជូនដំណឹង ព្រឹត្តិបត្រព័ត៌មានសុខភាព ទស្សនាវដ្តី និងរូបភាព សកម្មភាពការងាររបស់ថ្នាក់ដឹកនាំព្រឹទ្ធសភា លើគេហទំព័រព្រឹទ្ធសភាសរុបចំនួន១,៨៧៣ ចំណងជើង ។<br>+ការងារផ្សេងៗ:<br>- ថត និងផ្សព្វផ្សាយសកម្មភាពថ្នាក់ដឹកនាំក្នុង |

| | |
|---|---|
| | កម្មវិធីផ្សេងៗចំនួន១៥០លើក<br>- បានរៀបចំ និងបញ្ចូលលេខកូដឯកសារសៀវភៅច្បាប់ សៀវភៅជំនាញផ្សេងៗ និងចុះបញ្ជីឯកសារ បោះត្រា បិទប័ណ្ណខ្វី និងសងសៀវភៅ ជួសជុល និងផ្លាស់ប្តូរលេខកូដចាស់ៗសរុបចំនួន២,៨១៣ក្បាល<br>- បញ្ចូលទិន្នន័យសៀវភៅព្រឹទ្ធសភា អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ច្បាប់ កាសែត ទស្សនាវដ្តី ព្រឹត្តិបត្រ រាជកិច្ច ដាក់លេខកូដសៀវភៅថ្មី និង បញ្ចូលសៀវភៅតាម PMB E-Library បណ្តាញ Facebook សរុបចំនួន៦,១៨៨ ក្បាល ។ |

## II.ទិសដៅការងារឆ្នាំ២០១៨

បរិបទឆ្នាំ២០១៨

-បញ្ចប់នីតិកាលទី៣ (បើកនីតិកាលទី៤ សភាកម្ពុជាជាម្ចាស់ផ្ទះ (APPF) ឆ្នាំ២០១៩)

-ឆ្នាំនៃការបោះឆ្នោតព្រឹទ្ធសភា ថ្ងៃទី២៥ ខែកុម្ភៈ ឆ្នាំ២០១៨ បោះឆ្នោតសកល ថ្ងៃទី២៩ ខែកក្កដា ឆ្នាំ២០១៨ (មុខងារតំណាងដើរតួលើសលុប ឱកាស បណ្តុះបណ្តាល និងរៀបចំ)

-ឆ្នាំនៃកម្មវិធីនយោបាយថ្មីរបស់រាជរដ្ឋាភិបាលថ្មី

-ឆ្នាំបន្តនៃសមាហរណកម្មអាស៊ាន និងសកលភាវូបនីយកម្មដែលសហប្រតិបត្តិការតំបន់ និងអន្តរជាតិរបស់សភាកាន់តែសកម្ម

-ឆ្នាំដែលកម្ពុជាត្រូវពង្រឹងឋានៈជាប្រទេសចំណូលមធ្យមកម្រិតទាប ដែលឱកាសជីវភាព និង ប្រទេសជាតិល្អប្រសើរជាងមុន : (Social Regime and Social Assistance) ។

**១.មុខងារនីតិកម្ម**:

-ត្រៀមរៀបចំប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ សម័យប្រជុំពេញអង្គ និងប្រជុំវិសាមញ្ញព្រឹទ្ធសភា ប្រជុំគណៈកម្មការជំនាញ ប្រជុំអន្តរគណៈកម្មការផ្ទៃក្នុង ប្រជុំគណៈកម្មការពិសេស និងអន្តរស្ថាប័ន

-ការពិគ្រោះយោបល់ក្នុង និងក្រៅស្ថាប័ន ( ក្រសួង NGO OI ) សិក្ខាសាលា តុមូល សន្និសីទ បទបង្ហាញ វគ្គសិក្សា

-ការផ្លាស់ប្តូរបទពិសោធន៍ជាមួយសភាបរទេស ការតាមដានប្រតិទិនការងារ និងការងារ នីតិកម្ម របស់រដ្ឋសភា រាជរដ្ឋាភិបាល និងក្រសួងស្ថាប័ន

-ការពិនិត្យ និងផ្តល់យោបល់លើការកសាងច្បាប់ និងអនុវត្តច្បាប់ថវិការដ្ឋប្រចាំឆ្នាំជារៀងរាល់ឆ្នាំ

-បច្ចុប្បន្នភាពរដ្ឋធម្មនុញ្ញ បទបញ្ជាផ្ទៃក្នុង ក្រមសីលធម៌ ច្បាប់លក្ខន្តិកៈ ច្បាប់បោះឆ្នោត តួនាទី ភារកិច្ចសមត្ថកិច្ច និងយន្តការផ្សេងៗ

-ការសិក្សាចងក្រងកម្រងនីតិវិធីអនុវត្តមាត្រា ឬប្រការទាំងឡាយនៃគ្រប់បទដ្ឋានគតិយុត្តិពាក់ព័ន្ធនឹងតួនាទី ភារកិច្ច និងសមត្ថកិច្ចរបស់ព្រឹទ្ធសភា

-ការរៀបចំខួរក្បាលច្បាប់របស់ស្ថាប័ន: បណ្ណាល័យច្បាប់ និងបណ្ណសារដ្ឋានច្បាប់ ។

**២.មុខងារតាមដានការអនុវត្តច្បាប់ និងគោលនយោបាយ** :

-ត្រៀមសម្រួលការជួបសវនាការរវាងគណៈកម្មការជំនាញ និងក្រសួងស្ថាប័ននានា និងការចុះបេសកកម្មតាមបណ្តាខេត្ត-ក្រុង

-សម្របសម្រួលថវិការដ្ឋ ផែនការ គោលនយោបាយ ដើម្បីភាពត្រឹមត្រូវ ភាពរលូន គុណភាព និងប្រសិទ្ធភាពផង និងត្រៀមធ្វើបច្ចុប្បន្នភាពពេលមិនរលូន អនុវត្តមិនបាន មានប្រតិកម្មអវិជ្ជមានដោយផលប៉ះពាល់ច្រើនផង ឬក៏ហួសសម័យ: ប្រមូលព័ត៌មាន សិក្សា វាយតម្លៃ តម្រែតម្រង់ ផ្តល់អនុសាសន៍ និងក្នុងករណីចាំបាច់ស្នើវិសោធនកម្ម លុបចោល ឬបង្កើតថ្មី

-កម្មវិធីតាមដានការកសាងបទដ្ឋានក្រោមច្បាប់ ដើម្បីអនុវត្តច្បាប់ កម្មវិធីចុះតាមដានមើលវឌ្ឍនភាពនៃការអនុវត្តច្បាប់សំខាន់ៗ និងរសើបៗ និងដំណើរការផ្សព្វផ្សាយច្បាប់

-កម្មវិធីចុះតាមក្រសួង និងខេត្ត ក្រុង ឬថ្នាក់ក្រោមជាតិ ថ្នាក់ ឃុំ សង្កាត់ ស្រុក ខណ្ឌ ដើម្បីប្រមូលព័ត៌មានតាមវិស័យ ។

**៣.មុខងារតំណាង** :

-ត្រៀមរៀបចំជូនថ្នាក់ដឹកនាំព្រឹទ្ធសភា ចូលរួមក្នុងពិធីផ្លូវការនានា នៅតាមបណ្តាខេត្ត-ក្រុង

-ត្រៀមរៀបចំវេទិកាតាមភូមិភាគទាំង៨ សិក្ខាសាលា និងពិធីសំណេះសំណាលផ្លូវការផ្សេងៗ

-អន្តរាគមន៍តាមខ្សែបណ្តោយ និងខ្សែទទឹង ដើម្បីជួយដោះស្រាយកង្វល់ និងសំណូមពរច្រើនយ៉ាងជាតម្រូវការរបស់មូលដ្ឋាន

-ការចុះសាកសួរសុខទុក្ខប្រជាពលរដ្ឋ និងមូលដ្ឋាន

-ការដោះស្រាយតម្រូវការ និងសំណូមពរចាំបាច់របស់ប្រជាពលរដ្ឋ និងមូលដ្ឋាន

-ការងារសង្គមកិច្ច មនុស្សធម៌ សង្គ្រោះបន្ទាន់ វិភាគទាន កសាងហេដ្ឋារចនាសម្ព័ន្ធសមិទ្ធផលសង្គម ឬសាសនា ការរៀបចំបុណ្យទាន ការចុះចែកអំណោយ

-ការចងសម្ព័ន្ធភាពជាមួយអង្គភាពការពារព្រំដែន

-ការផលិតឯកសារ ខិត្តប័ណ្ណ សេចក្តីជូនដំណឹង សេចក្តីថ្លែងការណ៍ ទស្សនាវដ្តី ខ្សែវីដេអូផ្សព្វផ្សាយទូលំទូលាយ ការបើកបណ្ណាល័យសម្រាប់បម្រើសាធារណជនរួមទាំង E-library E-archives និងE-parliament

-ត្រៀមទទួលមន្ត្រីរាជការ យុវជន សិស្ស និស្សិត និងសាធារណជនមកទស្សនកិច្ចនៅព្រឹទ្ធសភា។

**៤.មុខងារសហប្រតិបត្តិការអន្តរជាតិ និងទំនាក់ទំនងសាធារណៈ**

-បដិសណ្ឋារកិច្ចគណៈប្រតិភូបរទេស និងអគ្គទូត ក្នុងនាមប្រមុខរដ្ឋស្តីទី ប្រធាន អនុប្រធានព្រឹទ្ធសភា និងប្រធានគណៈកម្មការ

-ការជួបប្រាស្រ័យជាមួយក្រសួង ស្ថាប័ន NGO, OI ដើម្បីទទួលព័ត៌មានអំពីសហប្រតិបត្តិការអន្តរជាតិតាមវិស័យ ស្ថានភាពនៃការអនុវត្តកិច្ចព្រមព្រៀងទ្វេភាគី និងពហុភាគីក្នុងវិស័យសិទ្ធិមនុស្ស ការប្រែប្រួលធាតុអាកាស ការអប់រំ ស្ត្រី កុមារ យេនឌ័រ សុខភាព និងស្បៀងអាហារ កម្មវិធីអភិវឌ្ឍសហប្រជាជាតិ WTO កម្មសិទ្ធិបញ្ញា បេតិកភ័ណ្ឌ និងដោយឡែកជាមួយក្រសួងការបរទេស សហប្រតិ-បត្តិការអន្តរជាតិ ដើម្បីទទួលព័ត៌មានរួមអំពីបញ្ហាតំបន់ និងអន្តរជាតិ និងគោលនយោបាយការបរទេសរបស់កម្ពុជា ការតាមដានមើលការអនុវត្ត SDG 17 ចំណុច COP 21 អនុសាសន៍ អ ស ប អំពីវិស័យសិទ្ធិមនុស្ស និងការអភិវឌ្ឍនៃទំនាក់ទំនង និងបញ្ហាតំបន់ និងអន្តរជាតិ ព្រមទាំងច្បាប់អន្តរជាតិ បដិសណ្ឋារកិច្ច គណៈប្រតិភូបរទេស និងអគ្គទូត បេសកជន គណៈប្រតិភូច្រើនកម្រិតៈ រដ្ឋ/សភា/ឯកជន ផ្លូវការ/មិនផ្លូវការ នយោបាយ/ឯកទេសខ្ពស់/មធ្យម/ទាប

-ត្រៀមរៀបចំបែបបទជូនថ្នាក់ដឹកនាំ និងសមាជិក សមាជិកាព្រឹទ្ធសភា រួមទាំងមន្ត្រីរាជការនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភាបំពេញបេសកកម្មក្រៅប្រទេស

-ការចូលរួមក្នុងគណៈប្រតិភូរាជរដ្ឋាភិបាល ដើម្បីតាមដានការងារសំខាន់ៗក្នុងក្របខ័ណ្ឌតំបន់ និងពិភពលោក

-ការចូលរួមក្នុងគណៈប្រតិភូអន្តរសភា ដើម្បីចូលរួមកិច្ចប្រជុំ វេទិកា សន្និសីទ តុមូល សិក្ខាសាលា មហាសន្និបាត IPU, APF, AIPA, APA, APPF, ASGPF, ASGP, CLV និងវេទិកាផ្សេងៗទៀត

-ការបង្កើតក្រុមមិត្តភាពទ្វេភាគី ក្រុមពហុភាគី និងក្រុមជាតិរបស់សភា ដើម្បីសហការ ការគាំទ្រ និងជំនួយ

-ការអនុវត្តដោយរស់រវើកតាមរយៈគំនិតផ្តួចផ្តើម និងការច្នៃប្រឌិតនូវការទូតសភាដែលអាចមានពហុវិស័យ និងពហុរូបភាព ដើម្បីការគាំទ្រខាងនយោបាយ ការទូត ជំនួយ និងសហប្រតិបត្តិការ (5 F : foreign Aid, foreign assistance, foreign investment, foreign trade and foreign tourist )

-ការផ្លាស់ប្តូរបទពិសោធន៍សភាក្នុងកម្រិតគណៈកម្មការ ឬសមាជិកសភា ឬអគ្គលេខាធិការដ្ឋាន ឬមន្ត្រី

-ការចុះ MOU ជាមួយសភា ឬរដ្ឋាភិបាលនៃប្រទេសជាមិត្ត ឬដៃគូ ដើម្បីសហប្រតិបត្តិការ ការគាំទ្រ ជំនួយ ឬសហប្រតិបត្តិការបច្ចេកទេស ឬការផ្លាស់ប្តូរបទពិសោធន៍សភា

-ការប្រើប្រាស់ជំនាញ ការស្រាវជ្រាវ និងឯកសារពីប្រភព OI, NGO ដើម្បីបំពេញតម្រូវការ

-ការសហការរៀបចំសិក្ខាសាលា តុមូល សន្និសីទ វេទិកា វគ្គបណ្តុះបណ្តាលជាមួយ Embassy, OI, NGO, ដៃគូក្នុង និងក្រៅប្រទេស ក្នុងក្របខ័ណ្ឌជាតិ ក្រោមជាតិ តំបន់ និងអន្តរជាតិ

-ការចូលរួមកម្មវិធីបុណ្យជាតិនៃប្រទេសជាមិត្ត(សារលិខិត និងកន្ត្រកផ្កា ការរំលែកទុក្ខ ការគោរពវិញ្ញាណក្ខន្ធ និងប័ណ្ណជូនពរ) និងពិធីជប់លៀងច្រើនកម្រិត ។

**៥.មុខងារអភិវឌ្ឍន៍ស្ថាប័ន** :

+ការងារគ្រប់គ្រងបុគ្គលិកៈ

-ចូលរួមកសាង និងរៀបចំនីតិវិធីអនុវត្តមាត្រាទាំងឡាយនៃរដ្ឋធម្មនុញ្ញ បទបញ្ជាផ្ទៃក្នុង ច្បាប់បោះឆ្នោត ច្បាប់លក្ខន្តិកៈសមាជិក មន្ត្រីរាជការនៃក្រុមនីតិប្បញ្ញត្តិ ក្រមសីលធម៌

-ការកសាងផែនការតម្រូវការធនធានមនុស្ស និងផែនការអភិវឌ្ឍធនធានមនុស្ស

-ការចាត់តាំង និងការផ្តល់គ្រឿងឥស្សរិយយសត្រូវអនុវត្តតាមគោលការណ៍ថ្មីនៃស្នាដៃ និងឯកទេស ការទទួលខុសត្រូវ ការគោរពច្បាប់ បទបញ្ជាផ្ទៃក្នុង វិន័យ សាមគ្គីភាព ឋានានុក្រម អតីតភាព លទ្ធផលនៃការសម្រេចការកិច្ច

-បន្តអនុវត្តការផ្ទេរ ការបង្វិល ការសាកល្បង ការវាយតម្លៃ ការប្រលង ការតាំងស៊ប់ ការដាក់វិន័យ ការព្យួរ ការបញ្ចប់ ការចូលនិវត្តតាមការកំណត់របស់ច្បាប់ជាធរមាន

-ការអភិវឌ្ឍខាងស្មារតី សំដៅការបំពាក់ស្ថាប័នដោយច្បាប់ លិខិតបទដ្ឋាន គោលការណ៍ គោលនយោបាយ ក្រមសីលធម៌ បរិយាកាសល្អ ត្រឹមត្រូវ យុត្តិធម៌ សមធម៌ ជឿនលឿន គោរពតាមនិយាមយេនឌ័រ និងស្តង់ដានៃសភាប្រជាធិបតេយ្យ ។ ប្រតិបត្តិការទាំងមូលត្រូវឈរលើនីតិរដ្ឋ អភិបាលកិច្ចល្អ មានតម្លាភាព និងគណនេយ្យភាពពិតប្រាកដ ។ ជ្រកក្រោមវប្បធម៌រៀនសូត្រជាប្រចាំ មន្ត្រីបុគ្គលិកត្រូវបានពូនជ្រំ ថែបំប៉នឲ្យទទួលបានការបណ្តុះបណ្តាលជាប់ជានិច្ចលើចំណេះដឹង ជំនាញ បច្ចេកវិទ្យា និងភាសា ហើយទទួលបានលើកទឹកចិត្តឲ្យក្លាយជាអ្នកអាជីពក្នុងការងារ ដែលអាចធ្វើការផ្តល់សេវា និងបង្កើតផលិតផលគាប់ប្រសើរ ដោយឯករាជ្យម្ចាស់ការពិតប្រាកដ ចេះគោរពច្បាប់ មានវិន័យ និងសុជីវធម៌ខ្ពស់ ហើយទទួលបានផលប្រយោជន៍ និងលាភសក្ការៈដោយថ្លៃថ្នូរ និងស័ក្តិសម ។ នេះជាក្របខ័ណ្ឌរួមនៃការងារនយោបាយ សតិអារម្មណ៍ និងចាត់តាំង ដែលត្រូវគ្របដណ្តប់ទៅលើគ្រប់អង្គភាពទាំងអស់ ដើម្បីធានា 3E'S ក្នុងការដឹកនាំ និងគ្រប់គ្រងតាមរយៈវដ្តនៃការធ្វើផែនការ ការចាត់តាំង ការដឹកនាំ និងការត្រួតពិនិត្យ

-សិក្សាការធ្វើបច្ចុប្បន្នភាពរចនាសម្ព័ន្ធសព្វថ្ងៃ ដើម្បីបើកផ្លូវដល់ការបើកទំព័រចាប់ប្រើប្រាស់អ្នកស្រាវជ្រាវ និងអ្នកឯកទេសប្រកបដោយគុណភាព និងប្រសិទ្ធភាព

-ការធ្វើសារពើភណ្ឌធនធានមនុស្ស និងជំនាញ

-ការគ្រប់គ្រងបានល្អប្រសើរនូវបេឡាសោធននិវត្តន៍ និងបេឡាបាត់បង់សមត្ថភាពវិជ្ជាជីវៈ សមាគមសង្គហៈសង្គ្រោះ របបសន្តិសុខសង្គម របបឧបត្ថម្ភសង្គម របបថែទាំសុខភាព របបត្រួតពិនិត្យសុខភាព និងរបបផ្សេងៗទៀត

-ការជំរុញការងារសង្គម ការងារយុវជន ការងារនារី និងយេនឌ័រ ការប្រយុទ្ធប្រឆាំងបាតុភាព

អសកម្ម អវិជ្ជមាននៅកន្លែងធ្វើការ ដូចការជក់បារី គ្រឿងញៀន ការប្រើប្រាស់បច្ចេកវិទ្យាព័ត៌មាន ធប់ធល់ ការប្រើប្រាស់ទឹក ភ្លើង ក្រដាស សម្ភារៈ បរិក្ខារ ដោយខ្ជះខ្ជាយ ការបោះសំរាមចោល ការមិនចូលរួមថែរក្សាបរិស្ថាន រហូតដល់ការគេចវេស ខ្ជិលធ្វើការ បាតុភាពឈប់ច្រើន និងមិនគោរពពេលម៉ោងធ្វើការ ដើររបោតរហូតក្នុងម៉ោងធ្វើការ ការសុំគ្រលំកូតករអំពីវត្តមាន ការអនុវត្តវិន័យ និងការវាយតម្លៃលំៗ ការខ្វាចពុំហ៊ានមានវិធានការ..ជំងឺ អន្តរាគមន៍ ការរើសអើង ការរំខាន.. ការអនុវត្តការប្រកាសទ្រព្យសម្បត្តិតាមច្បាប់ និងពេលវេលាកំណត់

+ការងារបណ្តុះបណ្តាលធនធានមនុស្ស:

-ការស្វះស្វែងរកជំនួយសម្រាប់ការលើកកំពស់សមត្ថភាព ចំណេះដឹង ជំនាញ បច្ចេកវិទ្យា និងភាសា តាមរយៈអាហារូបករណ៍ និងវគ្គវែង ខ្លី មធ្យម ក្នុង និងក្រៅប្រទេស ដើម្បីកសាងបាន៖

+ជួរអ្នកស្រាវជ្រាវខាងច្បាប់មួយក្រុម

+ជួរអ្នកស្រាវជ្រាវទូទៅមួយក្រុម

+ជួរអ្នកស្រាវជ្រាវខាងPBOមួយក្រុម

+ជួរអ្នកស្រាវជ្រាវខាងទំនាក់ទំនងអន្តរជាតិមួយក្រុម

+ជួរអ្នកឯកទេសខាងICTមួយក្រុម

+ជួរអ្នកឯកទេសខាងទំនាក់ទំនងសាធារណៈ និងព័ត៌មានមួយក្រុម

+ជួរអ្នកឯកទេសខាងការគ្រប់គ្រង និងបុគ្គលិក ផែនការ គណនេយ្យ សវនកម្ម លទ្ធកម្ម រដ្ឋបាល និងហិរញ្ញវត្ថុមួយក្រុម

+ជួរអ្នកដឹកនាំមួយក្រុម ដើម្បីត្រៀមបន្តវេនដោយល្អ និងរលូនមានសមត្ថភាព ឥទ្ធិពល និងគុណធម៌ខ្ពស់

-ការរៀបចំកម្មវិធីផ្លាស់ប្តូរបទពិសោធន៍ជាមួយសភានានា កម្មសិក្សា ការបណ្តុះបណ្តាលនៅនឹងកន្លែង ការចូលរួមកម្មវិធីរបស់វិទ្យាស្ថានសភាកម្ពុជា(PIC) ការចូលរួមសន្និសីទ សិក្ខាសាលា តុមូល ការពិគ្រោះយោបល់វគ្គសិក្សាក្នុង និងក្រៅប្រទេស ការទទួលអ្នកឯកទេសក្នុង និងក្រៅប្រទេស មកជួយបណ្តុះបណ្តាល

+ចាត់ចែងការងារកំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ:

-ការកសាងផែនការប្រតិបត្តិប្រចាំឆ្នាំរបស់គ្រប់អង្គភាព និងគ្រប់វិស័យ និងថវិកាតាមកម្មវិធីប្រចាំឆ្នាំ

-ត្រៀមខាងស្មារតី នយោបាយ សតិអារម្មណ៍ និងចាត់តាំង និងឯកសារចាំបាច់សម្រាប់នីតិកាលទី៤ ចូលរួមអនុវត្តកំណែទម្រង់ខាងរដ្ឋបាល និងហិរញ្ញវត្ថុតាមរយៈការកសាង ឬធ្វើបច្ចុប្បន្នភាព ច្បាប់ លិខិតបទដ្ឋាន គោលការណ៍ គោលនយោបាយ បទបញ្ជា ក្របខ័ណ្ឌ សន្ទស្សន៍បៀវត្ស តម្លៃសន្ទស្ស របបលាភការ បេឡាផ្សេងៗ...

-ការសិក្សាអំពីតម្រូវការធនធានមធ្យោបាយ និងហិរញ្ញវត្ថុដើម្បីពង្រឹងភាពស្អិតរមួត និងភាពរលូននៃប្រព័ន្ធសេវាពហុវិស័យ ឲ្យជានាបាន 3E's លើកត្តាសំខាន់ៗជាអាទិ៍: ល្បឿនទំនុកចិត្ត ជំនឿរបស់អតិថិជន

+ការកសាង និងជួសជុលហេដ្ឋារចនាសម្ព័ន្ធរូបវន្តរឹង-ទន់ ព្រមទាំងការងារផ្សេងៗ:

-ការអភិវឌ្ឍខាងរូបវន្ត សំដៅទីកន្លែងធ្វើការ សម្ភារៈ បរិក្ខារ ហេដ្ឋារចនាសម្ពន្ធ័រូបវន្ត (ទឹក ភ្លើង លូទឹក សំរាម ផ្លូវថ្នល់ ចំណតរថយន្ត កន្លែងហាត់ប្រាណ ភាពងាយស្រួលសម្រាប់ជនពិការ សួនច្បារ បណ្ណាល័យ និងបណ្ណសារដ្ឋានទំនើប..) និងហេដ្ឋារចនាសម្ព័ន្ធពេញលេញខាងបច្ចេកវិទ្យាព័ត៌មាន ដើម្បីជាកន្លែងទាក់ទាញ និងស័ក្តិសមដល់ជំនឿទុកចិត្តប្រជាពលរដ្ឋ ហើយសមាជិក និងបុគ្គលិកពេញចិត្តនឹងផាសុខភាព មនោរម្យភាពប្រកបដោយសន្តិសុខពេញលេញ បរិស្ថានល្អប្រសើរ និងមានស្តង់ដារ

-ការយកចិត្តទុកដាក់លើកផែនការ និងអនុវត្តការថែរក្សាបរិស្ថានរួម អគារ សួនច្បារ ឲ្យមានសោភ័ណភាព មនោរម្យភាព សុវត្ថិភាព និងសន្តិសុខពេញលេញប្រកបដោយហេដ្ឋារចនាសម្ព័ន្ធទាំងទន់ ទាំងរឹង ឲ្យដំណើរការបានជាប់លាប់ និងរលូនល្អ

-ចាត់ចែងសម្អាតអគារការិយាល័យថ្នាក់ដឹកនាំព្រឹទ្ធសភាថ្មី និងបន្តរកជំនួយកសាងសាលប្រជុំពេញអង្គថ្មី ត្រៀមសព្វយ៉ាងខាងរូបវន្តសម្រាប់នីតិកាលថ្មី អភិវឌ្ឍបច្ចេកវិទ្យាព័ត៌មាន និងផ្តល់ទីកន្លែងសម្រាប់បន្តបណ្តុះបណ្តាលធនធានមនុស្ស

-ត្រៀមរៀបចំជួសជុលសាលប្រជុំពេញអង្គ និងការិយាល័យសមាជិកព្រឹទ្ធសភា និងបំពាក់សម្ភារបរិក្ខារសម្រាប់ដំណើរការនីតិកាលទី៤ ដែលត្រូវបោះឆ្នោតនាថ្ងៃ២៥ ខែកុម្ភៈ ឆ្នាំ២០១៨

-រៀបចំប្លង់មេសម្រាប់ការអភិវឌ្ឍប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន E-library, E-archives, Studio , Security System,...

-រៀបចំប្លង់មេសម្រាប់ការអភិវឌ្ឍវិស័យព័ត៌មានទំនាក់ទំនងសាធារណៈ ប្លង់មេសម្រាប់ការអភិវឌ្ឍវិស័យ E-administration និងE-parliament ឬ WEBSITE របស់ស្ថាប័ន គណៈកម្មការ អគ្គនាយកដ្ឋាន ការកំណត់ Software ដើម្បីយកមកប្រើប្រាស់តាមតម្រូវការ ។

## II.សេចក្តីសន្និដ្ឋាន

ព្រឹទ្ធសភាបានបញ្ចប់ឆ្នាំចុងក្រោយនៃនីតិកាលទី៣ព្រឹទ្ធសភា បានដោយរលូន ប្រកបដោយកិត្តិយស ស្នាដៃ ជោគជ័យ និងលទ្ធផលល្អ ហើយមានសក្តានុពលគ្រប់គ្រាន់ ដើម្បីចាប់ផ្តើមនីតិកាលទី៤ ដែលតម្រូវឲ្យត្រៀមការងារពហុវិស័យជាមុនឲ្យបានគ្រប់ជ្រុងជ្រោយទាំងរូបវន្ត និងទាំងស្មារតី សម្រាប់នីតិកាលថ្មី ។ អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ក្នុងនាមជាសេនាធិការ បានណែនាំអនុវត្តភារកិច្ចថ្មីៗ ដែលគូសបញ្ជាក់អំពីសកម្មភាពទទួលខុសត្រូវរបស់មន្ត្រីរាជការគ្រប់លំដាប់ថ្នាក់ ។ ការបំពេញភារកិច្ច បានឆ្លុះបញ្ចាំងឲ្យឃើញនូវលទ្ធផលការងារសំខាន់ៗលើគ្រប់ការដ្ឋានវិស័យ និងគ្រប់យន្តការ/អង្គភាព ដែលបានដំណើរការដោយរលូន និងមានលទ្ធផលជាផ្លែផ្កា ។

ឆ្នាំ២០១៧នេះ ក្នុងបរិបទដែលមានការបោះឆ្នោតជ្រើសរើសសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ ថ្នាក់ដឹកនាំ សមាជិក សមាជិកាព្រឹទ្ធសភា បានយកចិត្តទុកដាក់ធ្វើសកម្មភាពឆ្ពោះទៅកាន់មូលដ្ឋាន តាមរយៈការរៀបចំវេទិកាសាធារណៈ កិច្ចពិគ្រោះយោបល់ ការឈ្វេងយល់អំពីវឌ្ឍនភាពជាវិជ្ជមាន ក្រោយរៀបចំវេទិកា ការចុះសាកសួរសុខទុក្ខ និងដឹកនាំក្រុមគ្រូពេទ្យចុះពិនិត្យព្យាបាលជំងឺជូន ប្រជាពលរដ្ឋ ព្រមទាំងចូលរួមចំណែកដល់ការអភិវឌ្ឍលើគ្រប់វិស័យនៅថ្នាក់ក្រោមជាតិ ។ ការងារ កិច្ចសហប្រតិបត្តិការអន្តរជាតិ មានថាមពលកាន់តែមមាញឹក ហើយមានលទ្ធផលផ្លែផ្កាជាគុណ ប្រយោជន៍ដល់ជាតិ និងស្ថាប័ន ។ វិទ្យាស្ថានសភាកម្ពុជា(PIC) បានបើកលទ្ធភាពថ្មី ដើម្បីឲ្យសមាជិកសភា និងមន្ត្រីទទួលបានទស្សនៈ និងបទពិសោធន៍ថ្មីក្នុងការងារសភា ។ ការអភិវឌ្ឍស្ថាប័នតាមរយៈការ ប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានកាន់តែទំនើប ដើម្បីផ្សព្វផ្សាយព័ត៌មានជូនថ្នាក់ដឹកនាំ សមាជិក សមាជិកាព្រឹទ្ធសភា មន្ត្រីរាជការនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ព្រមទាំងមហាជនទាំងអស់ឲ្យយល់ ដឹងអំពីដំណើរការវិវត្តការងាររបស់ព្រឹទ្ធសភាបានអនុវត្តល្អ និងទូលំទូលាយជាងមុន។

សមិទ្ធផលធំៗគឺ ការរួមចំណែកផលិតបាននូវសេចក្តីស្នើច្បាប់ស្តីពី ការបោះឆ្នោតជ្រើសតាំង សមាជិកព្រឹទ្ធសភា និងវិសោធនកម្មច្បាប់ស្តីពី លក្ខន្តិកៈមន្ត្រីរាជការនៃក្រុមនីតិប្បញ្ញត្តិ ព្រមទាំង រៀបចំបទបញ្ជាផ្ទៃក្នុងព្រឹទ្ធសភាសម្រាប់នីតិកាលថ្មី និងក្រមសីលធម៌សម្រាប់សមាជិកព្រឹទ្ធសភាផង ។ ក្នុងនោះការសម្រេចបាននូវគោលការណ៍ធ្វើសមាហរណកម្មមន្ត្រីរាជការទៅក្នុងក្របខ័ណ្ឌថ្មី តាមរយៈ ការធ្វើវិសោធនកម្មច្បាប់ស្តីពី លក្ខន្តិកៈមន្ត្រីរាជការនៃក្រុមនីតិប្បញ្ញត្តិ ព្រមទាំងបង្កើនផលប្រយោជន៍ សម្រាប់សមាជិកព្រឹទ្ធសភា មន្ត្រីរាជការ និងបុគ្គលិកជាប់កិច្ចសន្យា ។

ការត្រៀមប្រឈមនឹងការវិវត្តថ្មីៗក្នុងឆ្នាំ២០១៨ តម្រូវឲ្យមានការត្រៀមខ្លួនជាមុនឲ្យបានល្អ និងចេះបត់បែនតាមកាលៈទេសៈ និងពេលវេលាអាស្រ័យដោយឆ្នាំ២០១៨ មានការបោះឆ្នោតធំៗ ចំនួន០២លើក ។ ការបើកសម័យប្រជុំដំបូងគឺ ជាអាទិភាពខ្ពស់ក្នុងត្រីមាសទី១ ឆ្នាំ២០១៨ បន្ទាប់ពី ការបោះឆ្នោតព្រឹទ្ធសភានីតិកាលទី៤ នៅថ្ងៃទី២៥ ខែកុម្ភៈ ឆ្នាំ២០១៨ ។

ថ្ងៃ ចន្ទ ៧រោច ខែបុស្ស ឆ្នាំរកា ព.ស ២៥៦១

រាជធានីភ្នំពេញ, ថ្ងៃទី ៨ ខែមករា ឆ្នាំ២០១៨

**អគ្គលេខាធិការ**

អ៊ុំ សារិទ្ធ